ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការ

ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

លេខៈ ០១/០៥ គ.ទ.ក ស.ស.រ

# សេចក្តីសំរេច

## ស្តីពី

## ការជ្រើសរើសមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា

### ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១៣៥ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/១៩១ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/១២៩ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិក នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញសេចក្តីសំរេច លេខ ០២/០៤ គ.ទ.ក ស.ស.រ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីលក្ខខណ្ឌសំរាប់ការចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សា

- បានឃើញសេចក្តីសំរេច លេខ ០៤/០៤ គ.ទ.ក ស.ស.រ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

សេចក្តីសំរេចនេះមានគោលបំណង កំណត់អំពីលក្ខខណ្ឌជ្រើសរើស និងដំណើរការជ្រើសរើស មន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា ដើម្បីបំរើការងារក្នុងអនុគណៈកម្មការវាយតំលៃគុណភាពអប់រំឧត្តមសិក្សា ដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) ។

## ជំពូកទី ២

## លក្ខខណ្ឌជ្រើសរើស

**ប្រការ២.-**

លក្ខខណ្ឌជ្រើសរើសមានដូចខាងក្រោម :

១. បេក្ខជនទាំងពីរភេទត្រូវមានសញ្ញាប័ត្រចាប់ពីថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ឡើងទៅ

២. បេក្ខជនទាំងពីរភេទត្រូវមានបទពិសោធន៍ការងារក្នុងវិស័យសាធារណៈ ឬឯកជនយ៉ាងតិច ០៥ ឆ្នាំ

៣. បេក្ខជនទាំងពីរភេទត្រូវមានឯកទេសស្របនឹងជំនាញនានាដែលកំពុងបណ្តុះបណ្តាលនៅតាម គ្រឹះស្ថានឧត្តមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា

៤. បេក្ខជនទាំងពីរភេទត្រូវមានបុគ្គលិកលក្ខណៈ អត្តចរឹតសមរម្យ និងមានការទទួលខុសត្រូវលើការងាររបស់ខ្លួន ។

**ប្រការ៣.-**

**គ.ទ.ក** អាចជ្រើសរើសមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា មកពីសមាជិកនៃភ្នាក់ងារបណ្តាញគុណភាពអប់រំអាស៊ីប៉ាស៊ីហ្វិច (APQN) ឬសមាជិកនៃបណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN) ឬតំណាងមកពីអង្គការ SEAMEO RIHED និងមកពីស្ថាប័នទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានៃប្រទេសនានា ។

## ជំពូកទី ៣
## ដំណើរការនៃការជ្រើសរើស

**ប្រការ៤.-**

១. អគ្គលេខាធិការដ្ឋាន គ.ទ.ក ផ្សព្វផ្សាយជាសាធារណៈអំពីដំណើរការនៃការជ្រើសរើស និងទទួលពាក្យសុំចូលបំរើការងារជាមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា

២. អគ្គលេខាធិការដ្ឋាន គ.ទ.ក ធ្វើការណាត់ជួប និងធ្វើការសម្ភាសន៍

៣. អគ្គលេខាធិការដ្ឋាន គ.ទ.ក ផ្សព្វផ្សាយនូវបញ្ជីឈ្មោះបេក្ខជនដែលត្រូវបានជ្រើសរើស ជំហានដំបូង (Short List) ដើម្បីទទួលការបណ្តុះបណ្តាល

៤. អគ្គលេខាធិការដ្ឋាន គ.ទ.ក ធ្វើការបណ្តុះបណ្តាលបេក្ខជនដែលត្រូវបានជ្រើសរើសជំហានដំបូង

៥. អគ្គលេខាធិការដ្ឋាន គ.ទ.ក ផ្តល់លិខិតជូនដំណឹងទៅដល់បេក្ខជនដែលបានបណ្តុះបណ្តាល និងត្រូវបានជ្រើសរើសជាស្ថាពរ ។

## ជំពូកទី ៤
## អាណត្តិនៃមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា

**ប្រការ៥.-**

អាណត្តិរបស់មន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សាមានរយៈពេល ២ ឆ្នាំ ហើយអាចត្រូវបានជ្រើសតាំងសំរាប់អាណត្តិបន្ទាប់ដោយ គ.ទ.ក។ មន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា ត្រូវបានជ្រើសរើសអោយបំរើការងារមិនពេញម៉ោង ។

**ប្រការ៦.-**

មន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សា ដែលត្រូវបានតែងតាំងជាសមាជិកអនុគណៈកម្មការវាយតំលៃគុណភាពអប់រំឧត្តមសិក្សា អាចនឹងទទួលបានការឧបត្ថម្ភផ្សេងៗតាមការកំណត់របស់ គ.ទ.ក។

**ប្រការ៧.-**

មន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សាអាចត្រូវបានបញ្ឈប់មុនអាណត្តិ ក្នុងករណីណាមួយដូចខាងក្រោម :

- ត្រូវបានរកឃើញថាមានលក្ខណៈណាមួយដែលផ្ទុយនិងប្រការ ២ នៃសេចក្តីសំរេចនេះ
- ត្រូវបានផ្តន្ទាទោសជាស្ថាពរ ដោយតុលាការពីបទល្មើសព្រហ្មទ័ណ្ឌចាប់ពីថ្នាក់មជ្ឈឹមឡើងទៅ
- ផ្តល់របាយការណ៏ដែលមានគុណភាពទាបជាងការកំណត់របស់ គ.ទ.ក
- ពុំមានលទ្ធភាពធ្វើរបាយការណ៏អោយទាន់ពេលវេលា តាមការកំណត់របស់ គ.ទ.ក រយៈពេល ៣ ដង
- ប្រព្រឹត្តផ្ទុយនឹងក្រមសីលធមិរបស់អ្នកវាយតំលៃគុណភាពអប់រំ ដែលកំណត់ដោយ គ.ទ.ក។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ៨.-**

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី 18 ខែ ឧសភា ឆ្នាំ ២០០៥

**ត.ប ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**អគ្គលេខាធិការ**

**បណ្ឌិត ពិច សំណាង**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សមាជិក គ.ទ.ក
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ